# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៤៤

ដោយសារតែផ្នែកជំនុំជម្រះស្តីពីការប្រព្រឹត្តទៅលើក្រុមគោលដៅ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ បានឈានមកដល់ការបិទបញ្ចប់នោះ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឱកាសដល់ភាគី ដើម្បីធ្វើការបង្ហាញឯកសារគន្លឹះ ក្នុងសប្តាហ៍នេះ។ នេះ គឺជាការបើកសវនាការលើឯកសារគន្លឹះលើកទីបីក្នុងសំណុំរឿង០០២ វគ្គ២ និងបានគ្របដណ្តប់លើការប្រព្រឹត្តទៅលើជនជាតិភាគតិចចាមម៉ូស្លីម ជនជាតិភាគតិចវៀតណាម និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។[1] ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទលោក **នួន ជា** បានបដិសេធចូលរួមក្នុងសវនាការនាសប្តាហ៍នេះ ដែលប្រការនេះគឺជាការដើរចេញដូចនឹងសវនាការកាលពីខែកញ្ញា ឆ្នាំ២០១៥ កន្លងទៅផងដែរ។ ចំណែកឯភាគីផ្សេងទៀត បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ដោយបានធ្វើការបង្ហាញឯកសារគន្លឹះរបស់ពួកគេ រួមមាន៖ អត្ថបទសម្រង់ចេញពីសៀវភៅ ឯកសារគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ សារទូរលេខ អត្ថបទកាសែត និងឯកសារថតចម្លងនៃ *ទង់បដិវត្តន៍* របស់បក្សកុម្មុយនីស្តកម្ពុជា។ ការិយាល័យសហព្រះរាជអាជ្ញា បានបង្ហាញឯកសារមួយចំនួន ដើម្បីគាំទ្រនូវអំណះអំណាង ដែលថា

[1] សម្រាប់សេចក្តីសង្ខេបស្តីពីសវនាការលើឯកសារគន្លឹះលើកទីមួយ ក្នុងសំណុំរឿង០០២ វគ្គ២ ស្តីពីសហករណ៍ស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ *សូមមើល* របាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម ក្នុងសំណុំរឿង០០២ វគ្គ២ លេខ១៧ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី១៤ (ចុះថ្ងៃទី២៧ ដល់ ៣០ ខែមេសា ឆ្នាំ២០១៥)។ ចំណែកឯសវនាការលើឯកសារគន្លឹះបន្ទាប់ ត្រូវបានធ្វើឡើងនៅចុងបញ្ចប់នៃផ្នែកជំនុំជម្រះស្តីពីការដ្ឋានចំនួនបីនៅសម័យកម្ពុជាប្រជាធិបតេយ្យ *សូមមើល* របាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម ក្នុងសំណុំរឿង០០២ វគ្គ២ លេខ២៨ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី២៥ (ចុះថ្ងៃទី២៤-២៧ ខែសីហា ឆ្នាំ២០១៥) និងលេខ២៩ ស្តីពីសវនាការលើភស្តុតាង សប្តាហ៍ទី២៦ (ចុះថ្ងៃទី១-៣ ខែកញ្ញា ឆ្នាំ២០១៥)។

មានគោលនយោបាយថ្នាក់ជាតិ ក្នុងការកំណត់គោលដៅទៅលើក្រុមអតីតមន្ត្រីយោធា **លន់ នល់** និងការលុបបំបាត់ជនជាតិភាគតិចចាម និងវៀតណាម។ ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទលោក **ខៀវ សំផន** បានអះអាងថា ក្រុមទាំងនេះ គ្រាន់តែត្រូវបានកំណត់ជាក្រុមគោលដៅ ដោយហេតុផលថា ពួកគេបានបង្កើតឲ្យមានការគំរាមកំហែងទៅដល់របបកម្ពុជាប្រជាធិបតេយ្យនេះ ហើយក្រុមទាំងនេះក៏មិនត្រូវបានកំណត់ជាក្រុមគោលដៅ ដោយសារតែមានជាតិពន្ធ ឬសាសនារបស់ពួកគេឡើយ។ ក្រុមមេធាវីការពារ ក៏បានអះអាងផងដែរថា ពុំមានភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់ថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោក **ខៀវ សំផន** បានមានតួនាទីដោយមានឥទ្ធិពលធ្វើសេចក្តីសម្រេចណាមួយពាក់ព័ន្ធនឹងក្រុមទាំងបីនោះឡើយ។ នៅថ្ងៃសុក្រ ភាគីបានធ្វើការបង្ហាញពីការឆ្លើយតបរបស់ពួកគេ ទៅលើឯកសារដែលបានបង្ហាញដោយភាគីជំទាស់ ដោយបញ្ជាក់ពីភាពគួរឲ្យជឿជាក់បានទៅលើមូលដ្ឋានផ្សេងៗនៃការយោងលើឯកសារ មានដូចជា៖ អ្នកនិពន្ធ ឬក៏ផ្អែកទៅលើបរិបទដែលឯកសារទាំងនោះត្រូវបានបង្កើតឡើង។ មិនដូចគ្នាទៅនឹងសវនាការលើឯកសារគន្លឹះលើកមុន សវនាការលើកនេះមិនមានការលើកឡើងពីបញ្ហាគតិយុត្តសំខាន់ៗ ដែលនាំឲ្យមានការបង្អាក់ការវិវឌ្ឍនៃកិច្ចដំណើរការនីតិវិធីឡើយ ហើយដោយពុំមានវត្តមានក្រុមមេធាវីការពារក្តីឲ្យលោក **នួន ជា** ផងដែរនោះ សវនាការបានបញ្ចប់មុនពេលកំណត់ក្នុងសប្តាហ៍នេះ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ជា បូរ៉ាក់មុន្នី, គុំ សុមាលី, ដាញ៉ែល ម៉ាតើស (Daniel Matters), ខេតលីន កាហ្វប្រៀ (Caitlin McCaffrie), អេលីហ្សាបែត អ័រ (Elizabeth Orr), ធី ស៊ុន (Thi Son), តាយ លីណា និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (THE WSD HANDA Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University